ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

របាយការណ៍
កិច្ចប្រជុំរួមប្រចាំខែតុលា ឆ្នាំ២០២១
របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែតុលា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក អ្នកស្រី និងនាងកញ្ញាជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ជំនួយការ អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ តាមបណ្តាញវីដេអូ កម្មវិធី Zoom សរុបចំនួន៥១នាក់/គណនី។

គោលបំណងនៃកិច្ចប្រជុំដើម្បី ៖

- ធ្វើបច្ចុប្បន្នភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីស្ថានភាពរាលដាល និងការឆ្លើយតបនឹងមេរោគអេដស៍ ។
- ពិនិត្យ វាយតម្លៃពីសមិទ្ធផលដែលសម្រេចបាន និងឧបសគ្គក្នុងការអនុវត្តផែនការសកម្មភាពនិងដាក់ផែនការបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១) បទបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម ឃិនដារ៉ែត អគ្គលេខាធិការ។

២) បទបង្ហាញស្តីពីការគាំទ្រដល់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅថ្នាក់ជាតិនិងក្រោមជាតិ ដោយឯកឧត្តម **ជា ផល** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

៣) មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី។

៤) កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែតុលា ឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ខែវិច្ឆិកា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

I- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន

១- សកម្មភាពការងារដែលសម្រេចបាន ៖

- បានបញ្ចប់របាយការណ៍សង្ខេបស្តីពីសកម្មភាពការងារ ដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ជូនរាជរដ្ឋាភិបាល។
- បានបញ្ចប់របាយការណ៍ផ្ញើទៅក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ស្តីពីវឌ្ឍនភាពការងារសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧-២០២១) អំពីកិច្ចការពារសិទ្ធិស្ត្រី និងការលើកកម្ពស់សមភាពយេនឌ័រ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានរៀបចំរបៀបវារៈសម្រាប់កិច្ចប្រជុំពេញអង្គលើកទី២ និងរបៀបវារៈនៃសន្និបាតប្រចាំឆ្នាំ២០២១របស់ អ.ជ.ប.ជ.អ។
- បានរៀបចំរបៀបវារៈ សារ និងពាក្យស្លោក សម្រាប់ការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍។

២- បញ្ហាប្រឈម ៖

- ការអូសបន្លាយនៃការរាតត្បាតមេរោគកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការធ្វើអន្តរាគមន៍ និងការប្រមូលព័ត៌មាននៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- ព័ត៌មានហិរញ្ញប្បទានក្នុងការផ្តល់សាច់ប្រាក់របស់រាជរដ្ឋាភិបាល។

៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- ចុះអភិបាលតាមបណ្តាខេត្តនានា។
- បន្តរៀបចំផែនការសកម្មភាពថវិកា និងអនុវត្តសកម្មភាពសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ ក្រសួងស្ថាប័ន ពិសេស *គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (FTC)។
- ការរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ រៀបចំសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២១។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស
- ចាត់ចែងការចុះបញ្ជីបេឡាសាច់ប្រាក់ក្នុងធនាគារ និងក្នុងដៃសម្រាប់ខែវិច្ឆិកា។

II- **បទបង្ហាញស្តីពីការដឹកនាំដើម្បីបញ្ចប់ការរាលដាលជំងឺអេដស៍នៅកម្ពុជា**

ឯកឧត្តមវេជ្ជបណ្ឌិត **ង៉ា ថលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទទួលបន្ទុកបច្ចេកទេស បានបង្ហាញពីអាទិភាពនៃការសម្របសម្រួលក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ៖

- កិច្ចប្រជុំពិគ្រោះយោបល់ជាមួយ **ឯកឧត្តម កៅ ឧនដារ៉ា** ប្រធានគណៈកម្មាធិការអេដស៍ក្រសួងមហាផ្ទៃស្តីអំពី "**ការរួមចំណែករបស់ក្រសួងមហាផ្ទៃក្នុងការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍**" ដោយបានលើកសំណូមពរ៣ៈ ទី១) ភាពជាអ្នកដឹកនាំ គឺប្រព័ន្ធពង្រឹងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គណៈកម្មាធិការអេដស៍ខេត្ត/ស្រុក/ឃុំ) ពិនិត្យឡើងវិញនូវយន្តការថ្នាក់ក្រោមជាតិ ដើម្បីរួមបញ្ចូលតំណាងប្រជាជនគន្លឹះសំខាន់ៗ និងអ្នកផ្តួកមេរោគអេដស៍ ទី២) ភាពជាដៃគូ ដោយចូលរួម កិច្ចប្រជុំទៀងទាត់/របាយការណ៍របស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (គណៈកម្មាធិការខេត្ត/ស្រុក/ឃុំ) ជំងឺអេដស៍ ដោយមាន ការចូលរួមពីប្រជាជនគន្លឹះសំខាន់ៗ និងអ្នកផ្តួកមេរោគអេដស៍ ទី៣) ការវិនិយោគ ដោយផ្តល់មូលនិធិ ក្នុងស្រុកសម្រាប់ថ្នាក់ក្រោមជាតិ (គណៈកម្មា ធិការ អេដស៍ខេត្ត/ស្រុក/ឃុំ) ។
- ដើម្បីឆ្ពោះទៅបញ្ចប់ការរីករាលដាលមេរោគអេដស៍ ជំរុញការឆ្លើយតបអោយក្លាយជាចរន្តជាតិ ដោយធ្វើការពង្រឹងប្រព័ន្ធសុខាភិបាល ក្នុងពេលបន្តការអនុវត្តន៍កម្មវិធី។
- ពង្រឹងប្រព័ន្ធសុខភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីឱ្យក្លាយទៅជាម្ចាស់ក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងការគាំទ្រការអនុវត្តកម្មវិធី។
- ថ្នាក់ក្រោមជាតិ ត្រូវបង្កើនភាពម្ចាស់ការប្រើប្រាស់តួនាទីក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- កត្តាជោគជ័យគឺជម្រុញការទប់ស្កាត់ការរាតត្បាតឱ្យបាន៩៥% (៩៥% ទី១) នៅឆ្នាំ២០២៥។
- ពង្រឹងភាពជាអ្នកដឹកនាំ និងត្រូវធ្វើការផ្លាស់ប្តូរនូវភាពជាអ្នកដឹកនាំ។
- មន្ត្រីទាំងអស់ត្រូវមានជំនាញទន់ (Soft Skills)ក្នុងការដឹកនាំ និងគ្រប់គ្រង។ ក្នុងនោះ អ្នកដឹកនាំត្រូវចាប់ផ្តើមមើលទៅលើ សីលធម៌ និងក្រមសីលធម៌នៅក្នុងអ្នកដឹកនាំ។
- ត្រូវបញ្ចប់ការរីករាលដាលមេរោគអេដស៍ ដោយប្រើប្រព័ន្ធជាតិតែមួយ និងពង្រឹងប្រព័ន្ធការអនុវត្តន៍កម្មវិធី។
- ត្រូវប្រើប្រាស់ចំណុចគោលដៅសកល២០២៥ ក្នុងការពិនិត្យឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិ។

III)- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

១- ក្នុងកិច្ចប្រជុំពេញអង្គលើកទី២ ត្រូវបន្តទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន រាជធានី/ខេត្ត និងអង្គការដៃគូស្តីពីសកម្មភាពដែលបានធ្វើ និងផ្ញើរបាយការណ៍មកឱ្យអ.ជ.ប.ជ.អ ឱ្យទាន់ពេលវេលា ដើម្បីទទួលបានការលើកទឹកចិត្ត ក្នុងការផ្តល់មេដាយ ជូនប័ណ្ណសរសើរ ប័ណ្ណទទួលស្គាល់ការងារ ដោយយោងលើនីតិវិធីកំណត់លក្ខណសម្បត្តិនៃការផ្តល់រង្វាន់។

២- អគ្គលេខាធិការ ត្រូវជម្រាបជូនទៅក្រសួង ស្ថាប័ន រាជធានី/ខេត្ត ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសឱ្យផ្តល់របាយការណ៍ឱ្យបានទាន់ពេលវេលា ពីព្រោះឯកឧត្តមទេសរដ្ឋមន្ត្រីនឹងរាយការណ៍ជូនសម្តេចតេជោ ស្តីពីសមិទ្ធផលសម្រេចបានរបស់ក្រសួង ស្ថាប័ន រាជធានី/ខេត្ត។

៣- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទី និងការកិច្ចធំទូលំទូលាយក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ ដោយធ្វើការងារបញ្ចូលក្នុងប្រព័ន្ធជាតិតែមួយ(ទាំងក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ) ដូចជាអ្នកដែលបាត់បង់មិនចូលក្នុងប្រព័ន្ធព្យាបាលជំងឺអេដស៍ ។

៤- ត្រូវណែនាំដល់អង្គការសង្គមស៊ីវិល និងស្ថានទូត ដែលបានជួយដល់កម្មវិធីការងារអេដស៍ ត្រូវចូលមកតាម ប្រព័ន្ធជាតិតែមួយ(តាមរយៈគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រាជធានី ខេត្ត ស្រុក/ខណ្ឌ និងឃុំ/សង្កាត់)។

៥- *គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (Fast Track City) នឹងមានការប្រជុំរវាង អ.ជ.ប.ជ.អ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ក្នុងការធ្វើយ៉ាងណា ឱ្យមាននីតិវិធី ប្រើប្រាស់ថវិកាក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍ នៅឆ្នាំ២០២២ សម្រាប់រាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងបន្ទាយមានជ័យ បាន។

៦- អ.ជ.ប.ជ.អ ជាស្ថាប័នសម្របសម្រួលការងារប្រយុទ្ធនឹងជំងឺអេដស៍ទូទាំងប្រទេស ដូច្នេះនៅឆ្នាំ២០២៣ គឺបន្ត *គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (Fast Track City) ទៅខេត្តផ្សេងៗទៀត ដូចជា ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តដែលនៅតាមព្រំដែន។

៧- អគ្គលេខាធិការ ត្រូវរៀបចំបែងចែកភារកិច្ចសម្រាប់កិច្ចប្រជុំពេញអង្គលើកទី២ នឹងប្រព្រឹត្តទៅនាថ្ងៃទី២០ ខែធ្នូ និងអង្គសន្និបាតប្រយុទ្ធនឹងជំងឺអេដស៍នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

៨- អង្គការក្រៅរដ្ឋាភិបាលត្រូវធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ជាមួយអ.ជ.ប.ជ.អ ពិសេសតំណាងប្រជាជនគន្លឹះ គឺឱ្យគាត់មកប្រជុំក្នុងនាមជាអ្នកតំណាងពិតប្រាកដ និងធ្វើការងារជាមួយបណ្តាញរបស់អ.ជ.ប.ជ.អ គណៈកម្មាធិការអេដស៍ខេត្ត ស្រុក ឃុំ ។

៩- ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីអ.ជ.ប.ជ.អ ទៅជួយធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍នៅក្នុងក្រសួងមហាផ្ទៃ ដូច្នេះត្រូវពិភាក្សាគ្នាពីផែនការសកម្មភាពដើម្បីលើកទិសដៅ។ ទិសដៅទី១) រកឱ្យឃើញអ្នកដែលបាត់មុខ ឱ្យចូលក្នុងប្រព័ន្ធ ទី២) បង្ការការពារ កុំឱ្យរីករាលដាលនៃជំងឺអេដស៍។

១០- ពង្រឹងវិន័យ ឯកភាពផ្ទៃក្នុងរបស់អ.ជ.ប.ជ.អ នឹងមានការផ្លាស់ប្តូរតួនាទីបន្ថែមទៀត បើសិនជាថ្នាក់ដឹកនាំខ្លះនៅតែអសកម្ម។ មួយខែប្រជុំម្តង អ្នកខ្លះមិនចូលរួមប្រជុំផង លើសពីនេះទៅទៀតត្រូវប្រយ័ត្នប្រយែងក្នុងការផ្សព្វផ្សាយព័ត៌មានផ្ទៃក្នុង ទៅខាងក្រៅស្ថាប័ននាំឱ្យប៉ះពាល់កេរ្តិ៍ឈ្មោះស្ថាប័ន និងប៉ះពាល់ដល់កិត្តិយសរបស់ថ្នាក់ដឹកនាំ។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង ដោយមានការឯកភាពគ្នាជាធ្លុងមួយ មានសាមគ្គីភាពផ្ទៃក្នុងល្អ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:៣៨នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃអង្គារ ១២រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១
អ្នកធ្វើរបាយការណ៍

ស៊ុត_ថងជាន់

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី